វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

# មតិយោបល់របស់អង្គការមិនមែនរដ្ឋាភិបាល
# លើ
# សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

ត្រូវបានផ្ញើជូនៈ

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និង ខុទ្ទកាល័យនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១
- គ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ កាលពីថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១១

**រៀបចំដោយៈ**

**ក្រុមការងារនៃអង្គការមិនមែនរដ្ឋាភិបាលលើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ**

**ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១**

## ១. មតិយោបល់ទូទៅ

១.១ បើទោះជាពាក្យ "តម្លាភាព" និង "គណនេយ្យភាព" ត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ក្តី នីតិវិធីសម្រាប់ធានានូវតម្លាភាព និងគណនេយ្យភាពនៅមិនទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយទេ។ គួរតែមានអ្នកសង្កេតការឯករាជ្យ ឬពីខាងក្រៅក្នុងការតាមដានដំណើរការកិច្ចអនុវត្តលទ្ធកម្ម និងគួរមាន នីតិវិធីច្បាស់លាស់បន្ថែមទៀត ដើម្បីធានាតម្លាភាព និងគណនេយ្យភាព។

១.២ ប្រភេទនៃកិច្ចសន្យាជាច្រើនមិនត្រូវបានគ្របដណ្តប់ដោយច្បាប់នេះទេ រួមមានការលក់ ការជួល ការផ្ទេរ និងការចាត់ចែង ដទៃទៀតលើ ទ្រព្យសម្បត្តិរដ្ឋ ព្រមទាំង ការផ្តល់សម្បទាន ផ្សេងៗរបស់រដ្ឋដែលត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដោយឡែក។

១.៣ ច្បាប់នេះគួរកំនត់ថាវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែង ជាវិធីសាស្ត្រដេញថ្លៃលទ្ធកម្មដែលចង់បានបំផុតដែលគួរតែអនុវត្ត។ ស្រដៀងគ្នានេះដែរ ច្បាប់នេះគួរឱ្យនិយមន័យឱ្យបានច្បាស់ថែមទៀតចំពោះ "លក្ខខណ្ឌសម្រាប់ប្រើប្រាស់" វិធីសាស្ត្រក្រៅពីវិធីសាស្ត្រដេញថ្លៃដោយប្រកួត ប្រជែង។ លើសពីនេះទៀត ច្បាប់នេះគួរឱ្យនិយមន័យឱ្យបានច្បាស់លាស់នូវលក្ខណៈវិនិច្ឆ័យសម្រាប់ការសម្រេចចិត្តថា តើត្រូវប្រើប្រាស់ការដេញថ្លៃក្នុងស្រុក ឬអន្តរជាតិ និងរួមបញ្ចូលនីតិវិធីសម្រាប់ "ការចរចារដោយប្រកួតប្រជែង"។ (មាត្រា ១២ - ១៤)

១.៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានផ្តល់សិទ្ធិអំណាចដ៏ច្រើន។ មុខងារជាច្រើនដែលផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរត្រូវផ្តល់ជូនស្ថាប័នឯករាជ្យ។

១.៥ គួរមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ដើម្បីធ្វើការសម្រេចចិត្តថាតើត្រូវចុះបញ្ជីខ្មៅអ្នកដេញថ្លៃណាមួយ ឬទេ និងថាតើរយៈពេលប៉ុន្មាននៃការចុះបញ្ជីខ្មៅអ្នកដេញថ្លៃនោះ។ គួរមាននីតិវិធីច្បាស់លាស់ដែលអ្នកដេញថ្លៃដែលត្រូវបានចុះក្នុងបញ្ជីខ្មៅអាចធ្វើការប្តឹងតវ៉ាបាន។

១.៦ ការបញ្ចេញឯកសារដេញថ្លៃមុន ត្រូវតែហាមហាត់ ហើយអ្នកដេញថ្លៃទាំងអស់ត្រូវមានសិទ្ធិដូចគ្នាក្នុងការទទួលបាននូវព័ត៌មាន។ ដូចគ្នាដែរ នីតិវិធីនៃការបើកដេញថ្លៃគួរតែត្រូវពង្រឹងបន្ថែមទៀត។ (មាត្រា ៤០ និង៤៥)

១.៧ ខចែងទាក់ទងនឹងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាគួរត្រូវកែប្រែ ដើម្បីធានាថាប្រាក់កក់ធានានោះនឹង មិនត្រូវទាមទារសម្រាប់គ្រប់កិច្ចសន្យាទាំងអស់នោះទេ។ (មាត្រា ៤៩)

១.៨ តម្រូវការទាមទារដើម្បីចុះកិច្ចសន្យាបន្តឱ្យភាគីទីបីគួរត្រូវបន្ធូរបន្ថយ។ (មាត្រា ៦៤)

## ២. តារាងមតិយោបល់លម្អិតតាមជំពូក និងមាត្រា

| ជំពូក មាត្រា | មតិយោបល់របស់អង្គការសង្គមស៊ីវិលលើមាត្រា |
|---|---|
| **ជំពូក ១** | |
| មាត្រា ៣ | ចំនុចខាងក្រោមនេះគួរត្រូវគ្របដណ្តប់ដោយច្បាប់នេះផងដែរៈ<br>- កិច្ចលទ្ធកម្មដែលប៉ះពាល់ ..... ហើយដែលត្រូវមានការសម្រេច ពីគណៈរដ្ឋមន្ត្រី ឬ នាយករដ្ឋមន្ត្រី<br>- ការលក់ ការជួល ការផ្ទេរ និងការចាត់ចែង ដទៃទៀតលើ ទ្រព្យសម្បត្តិរដ្ឋ ព្រមទាំង ការផ្តល់សម្បទានផ្សេងៗ របស់ រដ្ឋដែល ត្រូវអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិដោយឡែក។ |
| **ជំពូក ២** | |
| មាត្រា ៥ | បញ្ហាមួយចំនួននៅក្នុងមាត្រា ៥ ដូចជាៈ<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនគួរមាន " សិទ្ធិអំណាច និងការទទួលខុសត្រូវ លើការរៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ" ទេ តែវាជាសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋសភាជាតិ។<br>• ស្ថាប័នដាច់ដោយឡែក ឯករាជ្យ ដែលមិនមែនជាក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានសិទ្ធិអំណាចដើម្បីៈ<br>o ដកហូតវិញនូវសិទ្ធិ ធ្វើការសម្រេចចិត្តរបស់ស្ថាប័នអនុវត្តលទ្ធកម្ម<br>o ដោះស្រាយជម្លោះលទ្ធកម្ម និង ការប្តឹងតវ៉ា<br>o ចុះឈ្មោះ និងចាត់ប្រភេទ និងចំណាត់ថ្នាក់ អ្នកដេញថ្លៃ ទៅក្នុងក៏រិត ផ្សេងៗគ្នា (មាត្រា ២៨) និងអ្នកដេញថ្លៃក្នុងបញ្ជីខ្មៅ (មាត្រា ៣១)<br>o ធ្វើសវនកម្មលើលទ្ធកម្មសាធារណៈ<br>• ប្រសិនបើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានអំណាចដូចមានចែងស្រាប់ អំណាច ទាំងនោះគួរតែមានក៏រិត។ ឧទាហរណ៍ៈ<br>o កាលៈទេសៈដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាច "ផ្តល់ ឬដកហូតនូវ សិទ្ធិនៃការធ្វើការសម្រេចចិត្ត របស់ស្ថាប័នអនុវត្តលទ្ធកម្ម" គួរតែ បញ្ជាក់ឱ្យបានច្បាស់លាស់។ |

| | |
|---|---|
| **ជំពូក ៣** | |
| មាត្រា ១០ | សមាជិកនៃគណៈកម្មាធិការលទ្ធកម្មគួរត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់។ សមាជិកទាំងនោះ មិនគួរជាបុគ្គលដែលប្រធានស្ថាប័នអនុវត្តលទ្ធកម្មជ្រើសរើសនោះទេ។<br><br>សមាជិកនៃគណៈកម្មាធិការលទ្ធកម្ម ក្រៅពីសមាជិកមានជំនាញហិរញ្ញវត្ថុ និងសមាជិកមានជំនាញបច្ចេកទេស គួររួមមានតំណាងពីសំណាក់សង្គមស៊ីវិល និងអ្នកប្រើប្រាស់។ |
| **ជំពូក ៤** | |
| មាត្រា ១១-១៤ និង ១៨ - ២៦ | លក្ខខណ្ឌសម្រាប់ការប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មជាក់លាក់ណាមួយ មិនទាន់ត្រូវបានកំនត់ច្បាស់លាស់នោះទេ។ |
| មាត្រា ១១ | ពាក្យ "កាលៈទេសៈពិសេស" ចាំបាច់ត្រូវមានការបញ្ជាក់ឱ្យបានច្បាស់លាស់។<br><br>"លក្ខខណ្ឌ កម្រិតទឹកប្រាក់ និងនីតិវិធីសម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មនីមួយៗ " មានសារៈសំខាន់គ្រប់គ្រាន់ នៅក្នុងច្បាប់នេះ មិនគួរនៅក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈទេ។ |
| មាត្រា ១២ | គួរបញ្ចូលនូវឃ្លាដែលគូសបន្ទាត់ពីក្រោម នៅក្នុងមាត្រាទី ១២:<br><br>... ក្នុងកិច្ចលទ្ធកម្មសាធារណៈ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈនឹងត្រូវបានប្រើប្រាស់លុះត្រា ណា ក). មិនមានប្រភពតែមួយគត់ ដែលមានសមត្ថភាពក្នុងការបំពេញការងារ នោះ ឬ ខ). មិនមានភាពបន្ទាន់ណាមួយដែលទាមទារនូវការផ្តល់កិច្ចសន្យាជាបន្ទាន់។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈរួមមាន:<br>ក. ... មានលក្ខណៈបច្ចេកទេសខ្ពស់ និងមិនមានអ្នកដេញថ្លៃក្នុងស្រុកគ្រប់គ្រាន់។<br>ខ. ...<br><br>លក្ខខណ្ឌថាតើនៅពេលណាដែលត្រូវប្រើប្រាស់ការដេញថ្លៃជាលក្ខណៈអន្តរជាតិ ឬក្នុងស្រុក |

| | |
|---|---|
| | មិនត្រូវបានកំនត់ច្បាស់លាស់ទេ។ |
| មាត្រា ១៤ | ច្បាប់នេះគួរចែងថា វិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែង គឺជាវិធីសាស្រ្តដែល ចង់បានជាងគេ និងគួរចែងឱ្យបានច្បាស់នូវលក្ខខណ្ឌកំណត់ ច្បាស់លាស់ថាតើ នៅពេលណាវិធីសាស្រ្តលទ្ធកម្មដោយឡែកអាចត្រូវបានអនុវត្ត។<br><br>ឃ្លា និងល្បះគូសបន្ទាត់ខាងក្រោមគួរត្រូវបន្ថែមក្នុងមាត្រា ១៤៖<br>... ដោយមិនមានការដេញថ្លៃដោយប្រកួតប្រជែង។ វិធីសាស្រ្តនេះ អាចអនុវត្តបាន លុះត្រាតែវិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែង មិនអាចអនុវត្តបាន និងមានការអនុញ្ញាតិជាមុនពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។<br><br>លទ្ធកម្មសម្រាប់ "គោលបំណងស្រាវជ្រាវ ការធ្វើពិសោធន៍ ឬការអភិវឌ្ឍន៍" គួរតែមានការដាក់ដេញថ្លៃដោយប្រកួតប្រជែង។<br><br>ចំនួនដងនៃការ " បន្តចុះកិច្ចសន្យា " ជាមួយអ្នក ទទួលការម៉ៅក់ (ឬកិច្ចសន្យាមួយ) គួរតែមានកំណត់។<br><br>ខចែងសំរាប់ " ការចរចារដោយប្រកួតប្រជែង" គួរត្រូវបន្ថែមនៅក្នុងមាត្រា។ |
| **ជំពូក ៥** | |
| មាត្រា ១៨ | វិធីសាស្រ្តជ្រើសរើសទីប្រឹក្សាគួររៀបតាមលំដាប់នៃវិធីជ្រើសរើសដែលចង់បាន។ |
| មាត្រា ២៥ | ថ្លៃគួរតែត្រូវបានដាក់បន្ថែមជាកត្តាមួយ លើការជ្រើសរើសទីប្រឹក្សា។ |
| **ជំពូក ៦** | |
| មាត្រា ២៨ | គួរបញ្ជាក់ឱ្យច្បាស់ថា ការចុះឈ្មោះធ្វើឡើងដោយមិនគិតថ្លៃ និងថាអ្នកដេញថ្លៃមិនអាចត្រូវបានបដិសេធការចុះឈ្មោះនេះបានទេ។<br><br>គួរដាក់បញ្ចូលថា អ្នកដេញថ្លៃនឹងត្រូវជូនដំណឹងអំពី ចំណាត់ប្រភេទ និងចំណាត់ថ្នាក់របស់ខ្លួន និងដាក់ |

| | |
|---|---|
| | បញ្ចូលដំណើរការ ដែលអ្នកដេញថ្លៃ អាចធ្វើការតវ៉ាបាន ។ |
| មាត្រា ៣១ | អង្គភាពដាច់ដោយឡែក និងឯករាជ្យ គួរមានការទទួលខុសត្រូវទាំងនេះ ។<br><br>ច្បាប់នេះត្រូវការបញ្ចូលនីតិវិធីសម្រាប់ការចុះបញ្ជីខ្មៅអ្នកដេញថ្លៃ និងលក្ខណៈវិនិច្ឆ័យ ដែលនឹងត្រូវប្រើដើម្បីសម្រេចថាតើអ្នកដេញថ្លៃនឹងត្រូវចុះក្នុងបញ្ជីខ្មៅ ឬទេ ។<br><br>រយៈពេលយូរបំផុតសម្រាប់ការចុះបញ្ជីខ្មៅ និងលក្ខណៈវិនិច្ឆ័យ ដែលនឹងត្រូវប្រើនៅពេលធ្វើការសម្រេចចិត្តថាតើ អ្នកដេញថ្លៃណាមួយគួរត្រូវលុបចេញពីបញ្ជីខ្មៅឬទេនោះ គួរត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ។<br><br>អ្នកដេញថ្លៃគួរត្រូវបានផ្តល់សិទ្ធិច្បាស់លាស់មួយ ដើម្បីប្តឹងតវ៉ាពីការចុះឈ្មោះក្នុងបញ្ជីខ្មៅ ។ |
| **ជំពូក ៧** | |
| មាត្រា ៣២ | គម្រោងលទ្ធកម្មជាមួយនឹងព័ត៌មានលម្អិតគួរតែជាឯកសារដែលអាចរកបានជាសាធារណៈ ។ |
| **ជំពូក ៨** | |
| មាត្រា ៣៩ | គួរបន្ថែមឃ្លាដូចមានគូសបន្ទាត់ពីក្រោម ក្នុងមាត្រា ៣៩ ដូចខាង ក្រោមនេះ:<br><br>អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំសេចក្តីជូនដំណឹង ស្តីពីការដេញថ្លៃសម្រាប់ធ្វើការផ្សព្វផ្សាយនៅលើគេហទំព័រ និងធ្វើការផ្សព្វផ្សាយដើម្បីជ្រើសរើសអ្នកដេញថ្លៃ ។ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃត្រូវមានព័ត៌មានសំខាន់ៗ ដូចខាងក្រោម:<br>- ការពណ៌នាលម្អិតអំពីប្រភេទ និងបរិមាណនៃទំនិញ ការងារសាងសង់ ការងារជួសជុល ឬសេវាកម្មដែលត្រូវធ្វើលទ្ធកម្ម<br>- ឈ្មោះ អាសយដ្ឋាន អ៊ីម៉ែល និង ទូរសាររបស់អង្គភាពលទ្ធកម្ម<br>- វិធីសាស្ត្រលទ្ធកម្មដែលត្រូវអនុវត្ត រួមបញ្ចូលទាំងលក្ខណៈនៃការវាយតម្លៃ<br>- ការតម្រូវឱ្យមាននូវលក្ខណៈសម្បត្តិ ឬ បុរេលក្ខណៈសម្បត្តិនានា... |
| មាត្រា ៤០ | គួរបន្ថែមនូវឈ្លះគូសបន្ទាត់ពីក្រោម ក្នុងមាត្រា ៤០ ដូចខាងក្រោម:<br><br>... បទដ្ឋាននៃឯកសារដេញថ្លៃមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។ |

| | |
|---|---|
| | ឯកសារដេញថ្លៃមិនត្រូវបញ្ចេញផ្សព្វផ្សាយ ខាងក្រៅស្ថាប័នអនុវត្តលទ្ធកម្មទេ រហូតទាល់មានសេចក្ដីជូនដំណឹងស្ដីពីការដេញថ្លៃ។ |
| មាត្រា ៤៣ | ប្រយោគដែលគូសបន្ទាត់ខាងក្រោមគួរត្រូវបន្ថែមនៅក្នុងមាត្រា ៤៣:<br><br>... ដោយអញ្ជើញអ្នកដេញថ្លៃ ដែលបានទទួលឯកសារដេញថ្លៃចូលរួម។ ឯកសារដេញថ្លៃអាចត្រូវធ្វើការកែប្រែ ប៉ុន្តែរយៈពេលសម្រាប់ការ ទទួលសំណើដេញថ្លៃគួរត្រូវពន្យាពេលសម្រាប់ពេលវេលាដ៏សមហេតុផល ដែលចាំបាច់សម្រាប់អ្នកដេញថ្លៃទាំងអស់ ដើម្បីមានឱកាសធ្វើការពិនិត្យឡើងវិញនូវការកែប្រែនៃឯកសារដេញថ្លៃនោះ និងធ្វើការកែប្រែនៅក្នុងសំណើដេញថ្លៃ។ ឯកសារដេញថ្លៃមិនអាចត្រូវធ្វើការកែប្រែឡើយ បន្ទាប់ពីការដាក់ជូនសំណើដេញថ្លៃ។ |
| មាត្រា ៤៥ | គួរបន្ថែមនូវឃ្លាគូសបន្ទាត់ពីក្រោម ក្នុងមាត្រា ៤៥ ដូចខាងក្រោម:<br><br>រាល់ឯកសារដេញថ្លៃត្រូវបើកភ្លាមៗជាសាធារណៈបន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ។ គ្មានសំណើដេញថ្លៃណាមួយនឹងត្រូវបើកមុនកាលបរិច្ឆេទកំណត់ទេ ហើយសំណើដេញថ្លៃណាមួយដែលទទួលបានបន្ទាប់ពី កាលបរិច្ឆេទកំណត់ទទួលនោះ ត្រូវបដិសេធចោល និងបញ្ជូនត្រលប់ទៅអ្នកដាក់សំណើវិញ ដោយមិនមានការបើក។ ព័ត៌មាន សំខាន់ៗ នៃសំណើដេញថ្លៃ ... |
| មាត្រា ៤៦ | គួរបន្ថែមនូវឃ្លាគូសបន្ទាត់ពីក្រោម ក្នុងមាត្រា ៤៦ ដូចខាងក្រោម:<br><br>.... នីតិវិធីវាយតម្លៃសំណើដេញថ្លៃ មានកំណត់ក្នុង វិធាន និងបទប្បញ្ញត្តិស្ដីពីលទ្ធកម្មសាធារណៈ។ គណៈកម្មាធិការ លទ្ធកម្មត្រូវបង្កើតនូវកំណត់ហេតុ ជាលាយលក្ខណ៍អក្សរ ស្ដីពីការវាយតម្លៃរបស់ខ្លួនទៅលើសំណើដេញថ្លៃទាំងអស់ និងមូលហេតុនៃការជ្រើសរើសអ្នកដេញថ្លៃដែលបានឈ្នះ។<br><br>នីតិវិធីនៃការបើកសំណើដេញថ្លៃមិនត្រូវបានកំនត់ន័យច្បាស់លាស់ទេ។ |
| មាត្រា ៤៨ | ពាក្យ និងឃ្លា ដែលមានគូសបន្ទាត់ពីក្រោមគួរតែ បន្ថែមក្នុងមាត្រា ៤៨:<br><br>បន្ទាប់ពីបញ្ចប់ការវាយតម្លៃសំណើរដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញសេចក្ដីជូនដំណឹងជាសាធារណៈ ស្ដីពីការសម្រេចប្រគល់កិច្ចសន្យា ទៅឱ្យអ្នកដេញថ្លៃដែលឈ្នះ ...... ត្រូវធ្វើឡើងក្រោយពេលមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវ |

| | |
|---|---|
| | ផ្តល់ជូនអ្នកដេញថ្លៃដែលចាញ់នូវសេចក្តីពន្យល់អំពីមូលហេតុដែលអ្នកដេញថ្លៃឈ្នះត្រូវបានជ្រើសរើស ។ |
| មាត្រា ៤៩ | វាហាក់ដូចជាថាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នឹងត្រូវទាមទារសម្រាប់គ្រប់លទ្ធកម្មទាំងអស់ ។ នេះមិនមែនជាបទដ្ឋាននៃការអនុវត្តល្អជាអន្តរជាតិទេ ព្រោះថាថ្លៃនៃការដាក់ជំនួសមិនខ្ពស់នោះទេ នៅក្នុងទីផ្សារមួយចំនួន ហើយប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដែលទាមទារ នៅគ្រប់លទ្ធកម្ម ទាំងអស់អាចជារនាំងចំពោះការហាក់ចូលទីផ្សាររបស់ក្រុមហ៊ុន ។ |
| **ជំពូក ១២** | |
| មាត្រា ៧៧ | គួរបញ្ជាក់ឱ្យច្បាស់ថាក្រុមហ៊ុនទទួលបានកិច្ចសន្យា និងបុគ្គលដែលទទួលខុសត្រូវនឹងត្រូវចុះ ក្នុងបញ្ជីខ្មៅ បើពុំដូច្នោះទេអ្នកដែលប្រព្រឹត្តខុសនោះនឹងបង្កើតក្រុមហ៊ុនមួយផ្សេងទៀត បើសិនជាក្រុមហ៊ុនមុន របស់បុគ្គលនោះត្រូវបានចុះក្នុងបញ្ជីខ្មៅ ។ |
| **ផ្សេងៗ** | |
| | • គួរមានដំណើរការលទ្ធកម្មដែលមានលក្ខណៈបទដ្ឋាន និងទម្រង់ដែលមានលក្ខណៈបទដ្ឋាន<br>• គួរមានការបណ្តុះបណ្តាលសម្រាប់សមាជិកគណៈកម្មាធិការលទ្ធកម្ម<br>• ការប្រព្រឹត្តល្មើស ការដាក់ទោស និងការទទួលខុសត្រូវគួរត្រូវរៀបរាប់ឱ្យបានក្បោះក្បាយ ។<br>• គណៈកម្មាធិការត្រួតពិនិត្យចំរុះ (A diversified Oversight Committee) គួរត្រូវបង្កើតឡើង ដើម្បីត្រួតពិនិត្យមើលការអនុវត្តច្បាប់នេះ ។<br>•គួរតែមានតម្រូវការ ដែលថាវិធាន និងបទប្បញ្ញត្តិត្រូវបង្កើតឱ្យបានឆាប់និងយោងយោបល់ខាងលើ ។ |

**បញ្ជីរាយនាមក្រុមការងារនៃអង្គការមិនមែនរដ្ឋាភិបាល**

**លើសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ**

| ល.រ | ឈ្មោះ | អង្គភាព |
|---|---|---|
| ១ | លោក ឈិត សំអាត<br>នាយកប្រតិបត្តិ | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ( មានសមាជិក ៨៣ អង្គការ និងមានសមាជិកបណ្តាញជាង ១៨០) |
| ២ | លោក សុខ សំអឿន<br>នាយកប្រតិបត្តិ | សម្ព័ន្ធដើម្បីសុច្ចរិតភាព និងគណនេយ្យភាពសង្គម ( មានសមាជិក ២៩ អង្គការ) |
| ៣ | លោក សាន ជ័យ<br>អ្នកសម្របសម្រួលបណ្តាញ | បណ្តាញរួបរួមដើម្បីគណនេយ្យភាពសង្គមអាស៊ីខាងកើត និងអាស៊ីប៉ាស៊ីហ្វិក (មានសមាជិក ១៣ អង្គការ) |
| ៤ | លោក លុន បូរិទ្ធី<br>នាយកប្រតិបត្តិ | គណកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ( មានសមាជិក ១២៦ អង្គការ) |
| ៥ | លោកស្រី ចេត ចរិយា<br>នាយិកាប្រតិបត្តិ | អង្គការ ស្តារកម្ពុជា ( មានបណ្តាញគាំទ្រ ដែលមានអង្គការមិនមែនរដ្ឋាភិបាលជាសមាជិក ២៧៣) |
| ៦ | លោក យ៉ង់ គឹមអេង<br>នាយកប្រតិបត្តិ | មជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍ និងសន្តិភាព |
| ៧ | លោកស្រី ធីដា ឃីះ<br>នាយិកាប្រតិបត្តិ | អង្គការសីលការ (Silaka) |
| ៨ | លោក ម៉ម សម្បត្តិ<br>ប្រធានក្រុមប្រឹក្សាភិបាល<br>នាយកប្រតិបត្តិ | សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន<br>អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) និង<br>បណ្តាញផលប៉ះពាល់សង្គមនិងបរិស្ថានពីឧស្សាហកម្ម<br>នីស្សារណកម្ម EISEI |
| ៩ | លោក ណែប ស៊ីនថៃ<br>នាយក | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) |
| ១០ | លោកវេជ្ជបណ្ឌិត ស៊ីន សុមុនី<br>នាយកប្រតិបត្តិ | អង្គការមេឌីខាំ MEDiCAM ( មានសមាជិក ១១៨ អង្គការ) |
| ១១ | លោកស្រី រស់ សុភាព<br>នាយិកាប្រតិបត្តិ | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) ( មានសមាជិកជាង ៦០ អង្គការ) |
| ១២ | លោក អ៊ិន ស៊ីរិទ្ធី<br>នាយកប្រតិបត្តិ | អង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល ( មានសមាជិក ១០៤ អង្គការ) |

| | | |
|---|---|---|
| ១៣ | លោកវេជ្ជបណ្ឌិត អ៊ុំ សុភាព<br>នាយកប្រតិបត្តិ | អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ (Khana) |
| ១៤ | លោក គល់ បញ្ញា<br>នាយកប្រតិបត្តិ | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី<br>និងយុត្តិធម៌នៅកម្ពុជា (Comfrel) |
| ១៥ | លោក មាស សំណាង<br>អគ្គលេខាធិការ | គណៈកម្មាធិកាអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ<br>(NGOCRC) ( មានសមាជិក ៤៩ អង្គការ) |
| ១៦ | លោក សួន សារ៉េត<br>នាយកលេខាធិការប្រតិបត្តិនៃ<br>គណៈកម្មាធិការប្រព្រឹត្តិកម្ម | គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិ<br>មនុស្សកម្ពុជា ( មានសមាជិក ២៣ អង្គការ) |
| ១៧ | លោក ជាង សុខា<br>នាយកប្រតិបត្តិ | កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) |
| ១៨ | លោកស្រី ប្រាក់ សុខានី<br>នាយិកា | អង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា |
| ១៩ | Andrew Boname<br>Chief of Party | វិទ្យាស្ថានគ្រប់គ្រងមជ្ឈឹមបូព៌ា |
| ២០ | Greg Priyadi<br>Country Director | Jesuit Service-Cambodia |